# នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង
# នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

**ព័ត៌មានពិស្តារនៃការដាក់ឯកសារ**

| | | |
|---|---|---|
| សំណុំរឿងលេខ | : | ០០២/១៩-០៩-២០០៧-អវតក/អជសដ |
| ដាក់ទៅ | : | អង្គជំនុំជម្រះសាលាដំបូង |
| ថ្ងៃដាក់ | : | ថ្ងៃទី៥ ខែធ្នូ ឆ្នាំ២០១៣ |
| ភាគីអ្នកដាក់ | : | សហព្រះរាជអាជ្ញា |
| ភាសាដើម | : | អង់គ្លេស |

ឯកសារបកប្រែ
TRANSLATION/TRADUCTION
ថ្ងៃ ខែ ឆ្នាំ (Date): 05-Dec-2013, 14:35
CMS/CFO: Sann Rada

**ចំណាត់ថ្នាក់ឯកសារ**

ប្រភេទឯកសារដែលស្នើឡើងដោយភាគីដាក់ឯកសារ: សាធារណៈ

ចំណាត់ថ្នាក់ឯកសារកំណត់ដោយអង្គជំនុំជម្រះសាលាដំបូង: សាធារណៈ/Public

ប្រភេទនៃចំណាត់ថ្នាក់ឯកសារ:

ការពិនិត្យឯកសារបណ្ដោះអាសន្នឡើងវិញ:

ឈ្មោះមន្ត្រីដែលបានពិនិត្យ:

ហត្ថលេខា:

---

## សេចក្តីសន្និដ្ឋានរបស់សហព្រះរាជអាជ្ញា ទាក់ទងនឹងវិសាលភាពនៃសំណុំរឿង ០០២/០២ និងការកំណត់កាលបរិច្ឆេទសវនាការ រួមជាមួយឧបសម្ព័ន្ធ ក

---

**អ្នកដាក់ឯកសារ:**
សហព្រះរាជអាជ្ញា
លោកស្រី ជា លាង
លោក Nicholas KOUMJIAN

**អ្នកទទួលឯកសារ:**
អង្គជំនុំជម្រះសាលាដំបូង
ចៅក្រម និល ណុន, ប្រធាន
ចៅក្រម Silvia CARTWRIGHT
ចៅក្រម យ៉ា សុខន
ចៅក្រម Jean-Marc LAVERGNE
ចៅក្រម យូ ឧត្តរា

**សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី:**
ពេជ អង្គ
Elisabeth SIMONNEAU FORT

**ចម្លងជូន:**
ជនជាប់ចោទ
នួន ជា
ខៀវ សំផន

**មេធាវីការពារក្តីជនជាប់ចោទ:**
លោក សុន អរុណ
លោក Victor Koppe
លោក គង់ សំអុន
លោក Arthur VERCKEN
Anta GUISSE

# សេចក្តីសន្និដ្ឋាន

១- ដើម្បីឆ្លើយតបទៅនឹងអនុស្សរណៈរបស់អង្គជំនុំជម្រះសាលាដំបូង ចុះថ្ងៃទី៨ ខែវិច្ឆិកា ឆ្នាំ២០១៣[1] និងសេចក្តីសម្រេចនាពេលថ្មីៗនេះរបស់អង្គជំនុំជម្រះតុលាការកំពូល ទាក់ទងនឹងការបំបែកកិច្ចដំណើរការនីតិវិធីនៃសំណុំរឿង០០២[2] សហព្រះរាជអាជ្ញាដាក់ជូនសំណើដូចតទៅនេះ អំពីវិសាលភាពនៃសំណុំរឿង០០២/០២ និងការកំណត់កាលបរិច្ឆេទសម្រាប់សវនាការនៃសំណុំរឿងនេះ។

## *ការកំណត់កាលបរិច្ឆេទសវនាការ*

២- អង្គជំនុំជម្រះតុលាការកំពូលបានបង្គាប់ថា សវនាការលើភ័ស្តុតាងក្នុងសំណុំរឿង០០២/០២ ចាប់ផ្តើម "ឆាប់ៗតាមដែលអាចធ្វើទៅបាន" និង "លឿនបំផុត" បន្ទាប់ពីកិច្ចប្រជុំរៀបចំសវនាការដែលបានកំណត់ធ្វើនៅថ្ងៃទី១១-១៣ ខែធ្នូ ឆ្នាំ២០១៣[3] នេះ។ តាមរយៈនេះ សហព្រះរាជអាជ្ញាស្នើថា សវនាការលើសំណុំរឿង០០២/០២ ត្រូវចាប់ផ្តើមនៅចុងខែកុម្ភៈ ឆ្នាំ២០១៤។ សហព្រះរាជអាជ្ញាកត់សម្គាល់ថា សេចក្តីសន្និដ្ឋានបើកការចោទចោទប្រកាន់ ដែលបានធ្វើក្នុងពេលចាប់ផ្តើមជំនុំជម្រះលើសំណុំរឿង ០០២/០១ នៅក្នុងខែវិច្ឆិកា ឆ្នាំ២០១១នោះ បានដោះស្រាយចំពោះបទចោទ និងឧក្រិដ្ឋកម្មទាំងអស់ដែលបានដាក់បញ្ចូលក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះ[4] នៃសំណុំរឿង០០២រួចហើយ។ តាមរយៈនេះដែរ សហព្រះរាជអាជ្ញាស្នើថាពុំចាំបាច់ធ្វើសេចក្តីសន្និដ្ឋានបើកការចោទប្រកាន់ទៀតទេ អនុលោមតាមវិធាន៨៩(២)*ស្ទួន* និងស្នើឲ្យអង្គជំនុំជម្រះសាលាដំបូងដំណើរការឲ្យបានឆាប់ដើម្បីស្តាប់សវនាការលើភ័ស្តុតាង។

---

[1] **E301** អនុស្សរណៈអង្គជំនុំជម្រះសាលាដំបូងដែលមានចំណងជើងថា "ការកំណត់កាលបរិច្ឆេទនៃកិច្ចប្រជុំរៀបចំសវនាការក្នុងសំណុំរឿង ០០២/០០២", ៨ វិច្ឆិកា ២០១៣។

[2] **E284/4/8** សេចក្តីសម្រេចលើបណ្តឹងសាទុក្ខភ្លាមៗប្រឆាំងនឹងសេចក្តីសម្រេចលើកទីពីរ របស់អង្គជំនុំជម្រះសាលាដំបូង ស្តីពីការបំបែកកិច្ចដំណើរការនីតិវិធីនៃសំណុំរឿង ០០២, ២៥ វិច្ឆិកា ២០១៣។

[3] **E284/4/8** សេចក្តីសម្រេចលើបណ្តឹងសាទុក្ខភ្លាមៗប្រឆាំងនឹងសេចក្តីសម្រេចលើកទីពីរ របស់អង្គជំនុំជម្រះសាលាដំបូង ស្តីពីការបំបែកកិច្ចដំណើរការនីតិវិធីនៃសំណុំរឿង ០០២, ២៥ វិច្ឆិកា ២០១៣, កថាខណ្ឌទី៧២, ៧៦។

[4] **E131** ដីកាកំណត់កាលបរិច្ឆេទនៃការធ្វើសេចក្តីសន្និដ្ឋានចោទប្រកាន់ និងសវនាការលើអង្គសេចក្តីនៃសំណុំរឿង ០០២, ១៨ តុលា ២០១១ ["ខណៈដែលដីកាសម្រេចបំបែកកិច្ចដំណើរការនីតិវិធីរបស់អង្គជំនុំជម្រះ ចុះថ្ងៃទី២២ ខែកញ្ញា ឆ្នាំ២០១១ (E124)] បំបែកកិច្ចដំណើរការនីតិវិធីទៅជាសវនាការតូចៗ គេបានគិតទុកថាសវនាការទីមួយនឹងផ្តល់នូវមូលដ្ឋានគ្រឹះជាទូទៅមួយសម្រាប់បទចោទទាំងអស់ រួមទាំងបទចោទដែលនឹងត្រូវលើកយកមកជជែកដោលនៅក្នុងសវនាការនាពេលក្រោយ។ ទន្ទឹមនេះ សហព្រះរាជអាជ្ញានឹងត្រូវបង្ហាញសេចក្តីសន្និដ្ឋានបើកការចោទប្រកាន់ដែលទាក់ទងនឹងបទចោទទាំងអស់ និងការចោទប្រកាន់អង្គហេតុទាំងអស់ប្រឆាំងនឹងជនជាប់ចោទនៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះ"។

៣- អង្គជំនុំជម្រះតុលាការកំពូលបានផ្តល់យោបល់បន្ថែមថា ប្រធានអង្គជំនុំជម្រះសាលាដំបូង "ត្រូវប្រើប្រាស់លទ្ធភាពដែលមានស្រាប់" ដើម្បីចាប់ផ្តើមឲ្យមានអង្គជំនុំជម្រះទីពីរ សម្រាប់ស្តាប់សវនាការលើសំណុំរឿង០០២/០២[5]។ សហព្រះរាជអាជ្ញាសន្និដ្ឋានថា "លទ្ធភាពដែលមានស្រាប់" គឺ ប្រធានបង្កើតអង្គជំនុំជម្រះមួយ ដោយយកចៅក្រមចេញពីចៅក្រមទាំងប្រាំពីររូប ដែលបច្ចុប្បន្នជាសមាសភាពនៃអង្គជំនុំជម្រះសាលាដំបូង ឬស្នើឲ្យមានការតែងតាំងចៅក្រមបន្ថែម បើសិនជាចំនួនចៅក្រមជាតិ និងអន្តរជាតិមិនមានគ្រប់ចំនួន ដើម្បីបង្កើតអង្គជំនុំជម្រះមួយសម្រាប់សំណុំរឿង០០២/០២។

៤- សវនាការមួយដែលបានដឹកនាំធ្វើឡើងដោយចៅក្រមស្តីទី ឬចៅក្រមបម្រុង ហើយដែលពួកគាត់ធ្លាប់បានដឹងអំពីភ័ស្តុតាង និងនីតិវិធីពីសំណុំរឿង០០២/០១ អាចដឹងច្បាស់នូវរបៀបមួយដែលមានប្រសិទ្ធិភាពយ៉ាងខ្លាំង និងដំណើរការបានលឿន ដើម្បីបញ្ចប់កិច្ចដំណើរការនីតិវិធីនៃសំណុំរឿង០០២ នេះ ហើយជាជម្រើសតែមួយគត់ដែលអាចរកបាន ដែលអាចឲ្យអង្គជំនុំជម្រះនេះអនុវត្តតាមសេចក្តីណែនាំរបស់អង្គជំនុំជម្រះតុលាការកំពូល "បានលឿនបំផុត" ក្នុងការចាប់ផ្តើមបើកសវនាការលើភ័ស្តុតាងក្នុងសំណុំរឿង០០២/០២។ ការប្រើប្រាស់នូវអង្គជំនុំជម្រះទីពីរ ដែលមានចៅក្រមសុទ្ធតែថ្មីទាំងអស់ មិនមែនជា "លទ្ធភាពដែលមានស្រាប់" ដែលប្រធាននៃអង្គជំនុំជម្រះសាលាដំបូងអាចរកបាននោះទេដោយហេតុថាចៅក្រមថ្មីចាំបាច់តម្រូវឲ្យមានការជ្រើសតាំងដោយអង្គការសហប្រជាជាតិ និង/ឬត្រូវបានអនុម័តយល់ព្រមដោយឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម។

៥- សេចក្តីសម្រេចចុះខែវិច្ឆិកា ឆ្នាំ២០១៣ របស់អង្គជំនុំជម្រះតុលាការកំពូលមិនបានដកគុណវុឌ្ឍិចៅក្រម ឬបានច្រានចោលចៅក្រមដដែល ដែលបានបានចូលរួមធ្វើការកាត់សេចក្តីក្នុងសំណុំរឿង០០២/០១ មិនឲ្យចូលរួមក្នុងអង្គជំនុំជម្រះទីពីរដែលនឹងត្រូវជំនុំជម្រះសំណុំរឿង០០២/០២នោះដែរ។ គ្មានមូលដ្ឋានខាងផ្លូវច្បាប់ក្នុងការសន្និដ្ឋានថាចៅក្រមទាំងនេះមិនអាចបំពេញនូវការទទួលខុសត្រូវខាងវិជ្ជាជីវៈ និងរក្សាបាននូវភាពមិនលម្អៀងរបស់ខ្លួន ក្នុងការស្តាប់សវនាការលើភ័ស្តុតាង និងការកាត់សេចក្តីលើ

---

[5] **E284/4/8** សេចក្តីសម្រេចលើបណ្តឹងសាទុក្ខភ្លាមៗប្រឆាំងនឹងសេចក្តីសម្រេចលើកទីពីរ របស់អង្គជំនុំជម្រះសាលាដំបូង ស្តីពីការបំបែកកិច្ចដំណើរការនីតិវិធីនៃសំណុំរឿង ០០២, ២៥ វិច្ឆិកា ២០១៣, កថាខណ្ឌទី៧៤។

បទចោទនៅក្នុងអង្គជំនុំជម្រះទីពីរនោះទេ ហើយការងាកចេញពីភារកិច្ចមិនលម្អៀងរបស់ខ្លួននេះ មិនអាចថាជាការ "ការសន្និដ្ឋានស្រាលៗ"[6] បានឡើយ។

៦- ខណៈដែលសេចក្ដីសម្រេចរបស់អង្គជំនុំជម្រះតុលាការកំពូល បានដាក់បញ្ចូលនូវសេចក្ដីណែនាំថា សវនាការលើភ័ស្ដុតាងក្នុងសំណុំរឿង០០២/០២ ត្រូវចាប់ផ្ដើម "ឆាប់ៗតាមដែលអាចធ្វើបាន" នោះ ការកិច្ចពិភាក្សាលើសេចក្ដីសម្រេចបង្កើតអង្គសវនាការជំនុំជម្រះទីពីរ មិនមែនជាផ្នែកមួយនៃដីកាសម្រេចនោះទេ។ ជាងនេះទៀត អង្គជំនុំជម្រះតុលាការកំពូលបានបញ្ជាក់យ៉ាងច្បាស់ថា សវនាការជំនុំជម្រះទីពីរ គឺចាំបាច់ប្រសិនបើអង្គជំនុំជម្រះបច្ចុប្បន្នមិនអាច ឬរកមិនបានចាប់ផ្ដើមស្ដាប់សវនាការលើភ័ស្ដុតាងនៃសំណុំរឿង០០២/០២ឲ្យបានឆាប់ទេ។ តាមកាលៈទេសៈបច្ចុប្បន្ន សហព្រះរាជអាជ្ញា មិនជឿថា ការបង្កើតអង្គជំនុំជម្រះទីពីរដែលមានសមាសភាពចៅក្រមថ្មី អាចពន្លឿនដល់ការចាប់ផ្ដើម ឬការបញ្ចប់សំណុំរឿង០០២/០២ ឲ្យបានឆាប់នោះឡើយ។

៧- ផ្ទុយទៅវិញ វាមិនអាចថា អង្គជំនុំជម្រះទីពីរ ដែលមានសមាសភាពសុទ្ធតែចៅក្រមថ្មី អាចនឹងត្រូវបង្កើតបានក្នុងពេលអនាគតឆាប់ៗនេះ ឬនៅមុនពេលអង្គជំនុំជម្រះដែលមានស្រាប់អាចបញ្ចប់ការធ្វើសេចក្ដីសម្រេចរបស់ខ្លួនលើសំណុំរឿង០០២/០១[7]។ នៅពេលបង្កើតបានហើយ អង្គជំនុំជម្រះទីពីរ ដែលមានសុទ្ធតែចៅក្រមថ្មី នឹងត្រូវការពេលវេលាយ៉ាងច្រើន ដើម្បីសិក្សាស្វែងយល់ទៅលើដីកាបញ្ជូនរឿងទៅជំនុំជម្រះ នៅលើប្រតិចារឹកសវនាការជាងពីរម៉ឺនបួនពាន់ទំព័រ និងលើភ័ស្ដុតាងជាឯកសារជាងមួយសែនទំព័រ ដើម្បីត្រៀមខ្លួនចាប់ផ្ដើមកិច្ចដំណើរការនីតិវិធីតាមផ្លូវច្បាប់ក្នុងសំណុំរឿង០០២/០២។

[6] សូមមើល *ក្នុងចំណោមឯកសារផ្សេងទៀត,* **សេចក្ដីសម្រេចពិសេស អបជ 02(3)5** លើសំណើរបស់ អៀង សារី សុំឲ្យមានវិធានការសមស្របទាក់ទងនឹងសេចក្ដីថ្លែងការណ៍ដោយនាយករដ្ឋមន្ត្រី ហ៊ុន សែន ក្នុងការតវ៉ាចំពោះឯករាជ្យភាពរបស់ចៅក្រមអង្គបុរេជំនុំជម្រះ Katinka Lahuis និង Rowan Downing, ៣០ វិច្ឆិកា ២០០៩, កថាខណ្ឌទី៦-៧។ **E55/4** សេចក្ដីសម្រេចលើបណ្ដឹងរបស់ អៀង ធីរិទ្ធ, នួន ជា និង អៀង សារី ដែលប្ដឹងជិតចិត្តចំពោះលោកចៅក្រម និល ណុន ចៅក្រម Silvia CARTWRIGHT ចៅក្រម យ៉ា សុខន ចៅក្រម Jean-Marc LAVERGNE និងចៅក្រម ធូ មណី, ២៣ មីនា ២០១១ ត្រង់កថាខណ្ឌទី១២។ **E137/5/1/3** សេចក្ដីសម្រេចលើបណ្ដឹងសាទុក្ខរបស់ អៀង សារី ប្រឆាំងនឹងសេចក្ដីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង ស្ដីពីបណ្ដឹងជិតចិត្ត លោកស្រីចៅក្រម SILVIA Cartwright, ១៧ មេសា ២០១២។ **E137/5** សេចក្ដីសម្រេចលើញត្តិស្នើសុំប្ដឹងជិតចិត្តចៅក្រម Silvia Cartwright, ២ ធ្នូ ២០១១។

[7] របៀបវារៈនៃកិច្ចប្រជុំរៀបចំសវនាការដែលបានបញ្ជូនមកភាគីនៅថ្ងៃទី៣ ខែធ្នូ ឆ្នាំ២០១៣ ថ្លែងថា: "ប្រធានប៉ាន់ប្រមាណថា សាលក្រមក្នុងសំណុំរឿង ០០២/០១ អាចនឹងត្រូវបានចេញនៅក្នុងអំឡុងត្រីមាសទីពីរនៃឆ្នាំ២០១៤"។ បើសាលក្រមនឹងចេញបាននៅក្នុងត្រីមាសទីពីរនេះមែន នោះវាទំនងជា ការសម្រេចចុងក្រោយរបស់ចៅក្រមនៃអង្គជំនុំជម្រះសាលាដំបូង ហើយនិងការដាក់ជូនសេចក្ដីព្រាងសាលក្រមសម្រាប់ការបកប្រែ ចាំបាច់ត្រូវបញ្ចប់ត្រឹមបំណាច់ត្រីមាសទីមួយនៃឆ្នាំ២០១៤។

៨- សហព្រះរាជអាជ្ញាទទួលស្គាល់ថា កាតព្វកិច្ចដើម្បីចាប់ផ្តើមសវនាការលើសំណុំរឿង០០២/០២ ឲ្យបានមុនពេលបញ្ចប់ ឬចេញសាលក្រមលើសំណុំរឿង០០២/០១ គឺជាការលំបាកមួយនៅលើធនធានរបស់អង្គជំនុំជម្រះសាលាដំបូង និងដូច្នេះជាការសំខាន់ថារដ្ឋបាលត្រូវធានាថា អង្គជំនុំជម្រះមានធនធានគ្រប់គ្រាន់សម្រាប់បំពេញកិច្ចការរបស់ខ្លួន។ សហព្រះរាជអាជ្ញានឹងប្រឈមមុខនឹងតម្រូវការផ្នែកធនធានយ៉ាងខ្លាំងផងដូចគ្នានេះដែរ ទាក់ទងនឹងសំណុំរឿង ០០៣ និង ០០៤ ដែលកំពុងតែធ្វើការស៊ើបសួរ និងក្នុងករណីមានបណ្តឹងសាទុក្ខលើសាលក្រមសំណុំរឿង០០២/០១។ សហព្រះរាជអាជ្ញាសង្កេតឃើញថា ជារឿងធម្មតាទេនៅក្នុងសាលាក្តីអន្តរជាតិដែលចៅក្រមត្រូវព្រាងសាលក្រមមួយហើយក្នុងពេលជាមួយគ្នា ពាក់ព័ន្ធក្នុងការស្តាប់សវនាការលើភស្តុតាងនៅក្នុងសវនាការទីពីរទៀត។ ជាពិសេស នៅក្នុងករណីដូចនេះនៅពេលដែលការព្រាងសាលក្រម ចាំបាច់ត្រូវការបកប្រែសិន ដើម្បីបានយកទៅពិភាក្សាគ្នា វាមិនអាចទេថា ចៅក្រមនៃអង្គជំនុំជម្រះនឹងពាក់ព័ន្ធនៅក្នុងការព្រាងសាលក្រមនៅគ្រប់ពេលទាំងអស់។ សហព្រះរាជអាជ្ញាស្នើបន្ថែមថា បន្ទុករបស់អង្គជំនុំជម្រះនេះអាចត្រូវបានសម្រាលតាមរយៈការកម្រិតកិច្ចដំណើរការនីតិវិធីសវនាការ មកត្រឹមបីថ្ងៃក្នុងមួយសប្តាហ៍ ក្នុងអំឡុងពេលដែលសាលក្រមនៃសំណុំរឿង០០២/០១ កំពុងព្រាង។

## *វិសាលភាពនៃការជំនុំជម្រះក្នុងសំណុំរឿង ០០២/០២*

៩- អង្គជំនុំជម្រះតុលាការកំពូលក៏បានបង្គាប់ផងដែរថា "សំណុំរឿង០០២/០២ ត្រូវមានបទចោទត្រឹមកម្រិតអប្បបរមាដែលពាក់ព័ន្ធនឹង ស-២១ ការដ្ឋានការងារមួយ សហករណ៍មួយ និងអំពើប្រល័យពូជសាសន៍"[8]។ ការណ៍នេះគឺដើម្បីធានាឲ្យប្រាកដថា "ការរួមបញ្ចូលគ្នានៃសំណុំរឿង០០២/០១ និង ០០២/០២ នឹងតំណាងឲ្យដីកាបញ្ជូនរឿងទៅជំនុំជម្រះ បានយ៉ាងសមរម្យ"[9]។ សេចក្តីសម្រេចរបស់អង្គជំនុំជម្រះតុលាការកំពូលបានកំណត់ពីកត្តា ឬលក្ខណៈវិនិច្ឆ័យជាធរមាន សម្រាប់ការកំណត់ភាពជាតំណាង ដោយកត់សម្គាល់ថា "គោលដៅបង្រួមទាំងមូល" នៃដំណើរការនេះ គឺដើម្បី "ជ្រើសរើស

---

[8] **E284/4/8** សេចក្តីសម្រេចលើបណ្តឹងសាទុក្ខភ្លាមៗប្រឆាំងនឹងសេចក្តីសម្រេចលើកទីពីរ របស់អង្គជំនុំជម្រះសាលាដំបូង ស្តីពីការបំបែកកិច្ចដំណើរការនីតិវិធីនៃសំណុំរឿង ០០២, ២៥ វិច្ឆិកា ២០១៣, កថាខណ្ឌទី៧៦។

[9] *ឯកសារដដែលដូចខាងលើ,* កថាខណ្ឌទី៧០។

យកចំនួនបទចោទដាក់លាក់ត្រឹមកម្រិតអប្បបរមា ដែលអាចឆ្លុះបញ្ចាំងបានសមស្របពីទំហំ និងប្រភេទនៃអំពើឧក្រិដ្ឋដែលបានចោទប្រកាន់ និងពិរុទ្ធភាពរបស់ជនជាប់ចោទ ទាំងអស់"[10]។

១០- អនុលោមតាមសេចក្តីបង្គាប់របស់អង្គជំនុំជម្រះតុលាការកំពូល សំណុំរឿង០០២/០២ ត្រូវតែដាក់បញ្ចូល ***មន្ទីរសន្តិសុខ ស-២១*** (រួមទាំងជើងឯក), ***អំពើប្រល័យពូជសាសន៍លើជនជាតិវៀតណាម*** និង ***អំពើប្រល័យពូជសាសន៍លើជនជាតិចាម***។ សេចក្តីណែនាំដែលថា សំណុំរឿងត្រូវតែដាក់បញ្ចូល "សហករណ៍" ក៏ផ្តល់អាណត្តិផងដែរឲ្យដាក់បញ្ចូលទីតាំងឧក្រិដ្ឋកម្ម ***សហករណ៍ត្រាំកក់*** ដែលជាសហករណ៍តែមួយគត់ដែលមាននៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះនៃសំណុំរឿង០០២។ អំពីលក្ខខណ្ឌតម្រូវឲ្យសំណុំរឿង០០២ បញ្ចូលផងដែរនូវ "ការដ្ឋានការងារ" នោះសហព្រះរាជអាជ្ញាធ្វើការសន្និដ្ឋានថា ***ការដ្ឋានទំនប់១មករា*** គួរបានជ្រើសរើសដោយអង្គជំនុំជម្រះសាលាដំបូង ដោយសារតែការដ្ឋាននេះ តំណាងឲ្យគម្រោងប្រព័ន្ធស្រោចស្រពខ្នាតធំ ដែលមានប្រជាជនកម្ពុជារាប់សែននាក់ត្រូវបានគេបង្ខំឲ្យធ្វើការនៅក្នុងសម័យកម្ពុជាប្រជាធិបតេយ្យ។

១១- សេចក្តីសម្រេចរបស់អង្គជំនុំជម្រះតុលាការកំពូលបញ្ជាក់ថា អង្គជំនុំជម្រះនេះមិនកាតព្វកិច្ចដាក់បញ្ចូលទីតាំងឧក្រិដ្ឋកម្មទាំងអស់ ឧប្បត្តិហេតុ ឬការចោទប្រកាន់ទាំងឡាយដែលទាក់ទងនឹងបទចោទប្រកាន់ជាពិសេសណាមួយ និងអាចកាត់បន្ថយចំនួននៃទីតាំងឧក្រិដ្ឋកម្ម ឬឧបត្តិហេតុនានាដែលភ័ស្តុតាងអំពីទីតាំង និងឧបត្តិហតុទាំងនេះ ត្រូវបានបង្ហាញថាជា "លិខិតុបករណ៍សម្រាប់ការរៀបចំសវនាការ"[11]។ ស្របគ្នាជាមួយនឹងវិធានផ្ទៃក្នុង និងការអនុវត្តរបស់តុលាការ *ពិសេសនានា* ស្តីពីការកាត់បន្ថយចំនួនទីតាំងឧក្រិដ្ឋកម្ម ឬឧបត្តិហេតុដែលអាចអនុវត្តបានជាធម្មតានៅក្នុងដំណើរការនីតិវិធីរឿងក្តីនៅ អវតក[12] ហេតុនេះហើយ សហព្រះរាជអាជ្ញាស្នើថា ការចោទប្រកាន់នានានៅក្នុងដីកាដំណោះស្រាយដែលទាក់ទងនឹង"ឧក្រិដ្ឋកម្មទាំងឡាយដែលបានប្រព្រឹត្តដោយកងទ័ពបដិវត្តកម្ពុជានៅលើទឹកដីវៀតណាម" (កថាខណ្ឌពីទី៨៣២-៨៤០) ត្រូវបានបំបែក និងដក ចេញពីក្នុងសំណុំរឿងលេខ០០២/០២ តួយ៉ាងដូចជា ការចោទប្រកាន់នានាដែលពាក់ព័ន្ធនឹងឧប្បត្តិហេតុដាច់ដោយឡែក ឬ

---

[10] *ឯកសារដដែលដូចខាងលើ,* កថាខណ្ឌទី៦៤។

[11] ឯកសារលេខ **E284/4/8** សេចក្តីសម្រេចលើបណ្តឹងសាទុក្ខភ្លាមៗប្រឆាំងនឹងសេចក្តីសម្រេចលើកទីពីររបស់អង្គជំនុំជម្រះសាលាដំបូងស្តីពីការបំបែកកិច្ចដំណើរការនីតិវិធីនៅក្នុងសំណុំរឿងលេខ០០២, ចុះថ្ងៃទី២៥ វិច្ឆិកា ២០១៣, កថាខណ្ឌទី៦៣។

[12] ឯកសារលេខ **E284/4/8** សេចក្តីសម្រេចលើបណ្តឹងសាទុក្ខភ្លាមៗប្រឆាំងនឹងសេចក្តីសម្រេចលើកទីពីររបស់អង្គជំនុំជម្រះសាលាដំបូងស្តីពីការបំបែកកិច្ចដំណើរការនីតិវិធីនៅក្នុងសំណុំរឿងលេខ០០២, ចុះថ្ងៃទី២៥ វិច្ឆិកា ២០១៣, កថាខណ្ឌទី៥៩ និងទី៦៣។

តាមលំដាប់លំដោយដែលមិនជាប់ទាក់ទងទៅនឹងអំពើប្រល័យពូជសាសន៍លើជនជាតិវៀតណាមដែលបានរស់នៅក្នុងកម្ពុជាប្រជាធិបតេយ្យនោះទេ។ ដោយមូលហេតុស្រដៀងគ្នានេះដែរ សហព្រះរាជអាជ្ញាស្នើថា ការចោទប្រកាន់ទាក់ទងនឹងមន្ទីរសន្តិសុខក្រូចឆ្មារ (កថាខណ្ឌពីទី៧៧១-៧៧៥) ត្រូវបំបែក និងដកចេញពីវិសាលភាពសំណុំរឿង០០២/០២។

១២- សហព្រះរាជអាជ្ញាស្នើឲ្យដាក់ការចោទប្រកាន់ពីបទធ្វើទុក្ខបុកម្នេញខាងសាសនា និងការចោទប្រកាន់ផ្សេងៗនៅក្នុងដីកាដំណោះស្រាយទាងទង់អំពីការបំបែក ឬ “ដាក់ឲ្យនៅបែកគ្នា” នៃប្រជាជនចាមនៅចុងឆ្នាំ១៩៧៥(កថាខណ្ឌទី២៦៦ ២៦៨ ២៨១ និង៧៥៨-៧៦១) ឲ្យចូលជាផ្នែកនៅក្នុងសំណុំរឿងលេខ០០២/២។ អង្គជំនុំជម្រះសាលាដំបូងបានដកចេញពីក្នុងវិសាលភាពនៃការជំនុំជម្រះក្តីវគ្គទីមួយនូវការចោទប្រកាន់ពីបទធ្វើទុក្ខបុកម្នេញខាងសាសនា និងអំពើប្រល័យពូជសាសន៍ទាក់ទងនឹងការជម្លៀសជនជាតិចាម[13]។ បទចោទ និងការចោទប្រកាន់ទាំងនេះ គួរតែបានដាក់បញ្ចូលជាផ្នែកមួយនៃសំណុំរឿងលេខ០០២/២ ដោយសារបទចោទ និងការចោទប្រកាន់ទាំងនេះពាក់ព័ន្ធនឹងអង្គហេតុ និងភស្តុតាង សំខាន់ក្នុងការបង្ហាញឲ្យឃើញពីគោលនយោបាយរបស់មេដឹកនាំបក្សកុម្មុយនីស្តកម្ពុជាក្នុងការធ្វើទុក្ខបុកម្នេញចំពោះជនជាតិចាម ហើយហេតុដូចនេះគឺជាការជាប់ទាក់ទងដោយផ្ទាល់ទៅនឹងការចោទប្រកាន់ពីបទអំពើប្រល័យពូជសាសន៍ប្រឆាំងនឹងជនជាតិចាម[14]។

១៣- ទាក់ទងនឹងទីតាំងឧក្រិដ្ឋកម្មនានានៅ*សហករណ៍ត្រាំកក់* សហព្រះរាជអាជ្ញាស្នើឲ្យដាក់បញ្ចូលមន្ទីរសន្តិសុខស្រុកត្រាំកក់ (ក្រាំងតាចាន់) ជាផ្នែកមួយនៃសំណុំរឿងលេខ០០២/០២។ នៅក្នុងផ្នែកស្តីពី*សហករណ៍ត្រាំកក់* នៃដីកាដំណោះស្រាយ មានការចោទប្រកាន់ជាច្រើនទាក់ទងនឹង ការចាប់ខ្លួនឃុំខ្លួន សួរចម្លើយ និងការធ្វើទារុណកម្មខ្លាំងនៅក្នុងស្រុកត្រាំកក់ និងការប្រើមន្ទីរអប់រំកែប្រែនានាដូចជា ក្រាំងតាចាន់[15] ដែលរួមបញ្ចូលទាំងចំណងជើងតូចថា “សន្តិសុខ”[16]។ ការចោទប្រកាន់ទាំងនេះ

---

[13] ឯកសារលេខ **E284** សេចក្តីសម្រេចស្តីពីការបំបែកកិច្ចដំណើរការនីតិវិធីនៅក្នុងសំណុំរឿងលេខ០០២ បន្ទាប់ពីសេចក្តីសម្រេចរបស់អង្គជំនុំជម្រះតុលាការកំពូលចុះថ្ងៃទី៨ កុម្ភៈ ២០១៣, ចុះថ្ងៃទី២៦ មេសា ២០១៣, កថាខណ្ឌទី១៥៩, កំណត់សម្គាល់នៅលេខយោងជើងទំព័រលេខ ២៦៧។ឯកសារលេខ **E124/7.3** បញ្ជីនៃកថាខណ្ឌ និងផ្នែកនៃដីកាដំណោះស្រាយដែលពាក់ព័ន្ធនឹងសំណុំរឿងលេខ០០២/០១, កថាខណ្ឌទី៤, កំណត់សំគាល់នៅលេខយោងជើងទំព័រ លេខ១។

[14] *សូមអាន ឧទា. ដូចជា* ឯកសារលេខ **D427** ដីកាដំណោះស្រាយ, ចុះថ្ងៃទី១៥ កញ្ញា ២០១៣, កថាខណ្ឌទី៧៥១ និងទី៧៥៨-៧៦១។

[15] ឯកសារលេខ D427 ដីកាដំណោះស្រាយ, កថាខណ្ឌទី៣០៩ [កិច្ចប្រជុំស្តីពីការបោសសំអាតខ្មាំង], ៣១១ [អ្នកដែលខកខាន ឬដែលបានបដិសេធមិនព្រមធ្វើឲ្យគ្រប់តាមផែនការ ត្រូវបានគេចាប់ខ្លួននិងធ្វើការអប់រំកែប្រែ], ៣១២ នាក់ [“ការចាប់ខ្លួនអ្នកដែលរអ៊ូរទាំអំពីការងារនិងអំពិស្ថានភាពរស់នៅតាមសហករណ៍នានា”], 315 [អ្នកដែលត្រូវធ្វើការអប់រំកែប្រែ ត្រូវបាន “ចាប់ខ្លួនដោយកងឈ្លបភូមិ និងបញ្ជូនទៅ

គាំទ្រចំពោះបទចោទនៃឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ដូចជា ការដាក់នៅក្នុងមន្ទីរឃុំឃាំង ការធ្វើទារុណកម្ម ការធ្វើទុក្ខបុកម្នេញខាងនយោបាយ និងការបាត់ខ្លួនដោយបង្ខំ ដែលធ្វើឡើងប្រឆាំងនឹងជនជាប់ចោទពាក់ព័ន្ធទៅនឹងទីតាំង*សហករណ៍ត្រាំកក់*[17]។ ហេតុដូចនេះ ដើម្បីឲ្យការកាត់ក្តីបានត្រឹមត្រូវ និងពេញលេញលើបទចោទនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិទាក់ទងនឹងទីតាំងឧក្រិដ្ឋកម្មនេះ អង្គជំនុំជម្រះសាលាដំបូងចាំបាច់ទទួលយក និងពិចារណាលើភស្តុតាងដែលទាក់ទងនឹងមន្ទីរសន្តិសុខស្រុកត្រាំកក់ ហើយដូច្នេះគួរតែដាក់បញ្ចូលនូវទីតាំងឧក្រិដ្ឋកម្មនៃ***មន្ទីរសន្តិសុខក្រាំងតាចាន់*** (កថាខណ្ឌទី៤៨៩-៥១៥) នៅក្នុងវិសាលភាពនៃសំណុំរឿងលេខ០០២/០២។

១៤- សហព្រះរាជអាជ្ញាធ្វើការកត់សម្គាល់ថា ឧក្រិដ្ឋកម្មនានា ដែលទាក់ទងទៅនឹងការធ្វើបាបចំពោះពុទ្ធសាសនិកជន និងការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ ក៏គួរតែត្រូវបានដាក់បញ្ចូល និងជំនុំជម្រះផងដែរតាមរយៈ *សហករណ៍ត្រាំកក់* ថាជាបទឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិប្រឆាំងនឹងជនជាប់ចោទដែលពាក់ព័ន្ធទៅនឹងទីតាំងនោះ រួមបញ្ចូលទាំងការធ្វើទុក្ខបុកម្នេញខាងសាសនាទៅលើពុទ្ធសាសនិកជន[18] ព្រមទាំងអំពើអមនុស្សធម៌ផ្សេងៗទៀតតាមរយៈការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ[19]។ការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ គួរបានដាក់បញ្ចូលផងដែរជាឧក្រិដ្ឋកម្មមួយក្នុងចំណោមឧក្រិដ្ឋកម្មនានាដែលបានចោទប្រកាន់ទាក់ទងទៅនឹង*ការដ្ឋានពលកម្មទំនប់១មករា*ផងដែរ[20]។ នៅពេលសហព្រះរាជអាជ្ញាមិនបានស្នើឲ្យដាក់បញ្ចូលវត្តនៅតាមតំបន់នានានៃទូទាំងប្រទេសចូលក្នុងទីតាំងឧក្រិដ្ឋកម្ម[21] និងមិនដាក់បញ្ចូលការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំនៅគ្រប់តំបន់ទាំងអស់ក្នុងផ្ទៃប្រទេស នោះសហព្រះរាជអាជ្ញាស្នើឲ្យដាក់បញ្ចូលនូវការចោទប្រកាន់ទូទៅ នៅក្នុងដីកាដំណោះស្រាយទាក់ទងនឹងការធ្វើបាបចំពោះពុទ្ធសាសនិកជន(កថាខណ្ឌទី៧៤០-៧៤៣) និងការដាក់បទបញ្ញាលើអាពាហ៍ពិពាហ៍ (កថាខណ្ឌទី៨៤២-៨៦០)។ ការណ៍នេះនឹងធានាឲ្យប្រាកដថាភស្តុតាងទូទៅអាចត្រូវបានប្រើ

កាន់មន្ទីរសន្តសុខក្រាំងតាចាន់”], 317 [ការចាប់ខ្លួន, ការឃុំខ្លួន, សួរចម្លើយនិងធ្វើទារុណកម្មពួកអ្នកទោស], 318 [ការបាត់ខ្លួននៃពួកអ្នកស្រុកដែលមានទីលំនៅនៅត្រាំកក់]។

16 *ដូចខាងលើ* ត្រង់កថាខណ្ឌទី៣១៥-៣១៨។

17 *ដូចខាងលើ* ត្រង់កថាខណ្ឌទី១៤០២, ១៤០៨, ១៤១៦, ១៤១៨, ១៤៧០។

18 ឯកសារលេខ **D427** ដីកាដំណោះស្រាយ, កថាខណ្ឌទី ៣១២,១៤២១។

19 *ដូចខាងលើ* ត្រង់កថាខណ្ឌទី៣១៤, ១៤៤២។

20 *ដូចខាងលើ* ត្រង់កថាខណ្ឌទី៣៦១, ១៤៤២។

21 *សូមអាន* ឯកសារលេខ **D427** ដីកាដំណោះស្រាយ, កថាខណ្ឌទី ៧៤៣ [ដែលជាបញ្ជីរៀបរាប់អំពីវត្តចំនួនប្រាំបី ពីតាមភូមិភាគនិងតំបន់ផ្សេងៗ]។

ប្រាស់ ដើម្បីបង្ហាញឲ្យឃើញអំពីគោលនយោបាយរបស់ បកក លើបញ្ហាទាំងនេះ, អំពីអត្ថិភាពនៃសហឧក្រិដ្ឋកម្មរួម និងអំពីលក្ខណៈទូលំទូលាយ និងជាប្រព័ន្ធនៃប្រភេទឧក្រិដ្ឋកម្ម ដើម្បីគាំទ្រចំពោះបទចោទប្រកាន់នានាប្រឆាំងនឹងជនជាប់ចោទទាក់ទងទៅនឹង*សហករណ៍ត្រាំកក់ និងការដ្ឋានទំនប់១មករា*។

១៥- បន្ថែមពីលើទីតាំងឧក្រិដ្ឋកម្មនានា ឬឧប្បត្តិហេតុនានាដូចដែលបានលើកឡើងខាងលើនេះ (មន្ទីរស-២១, អំពើប្រល័យពូជសាសន៍លើជនជាតិវៀតណាម និងជនជាតិចាម, សហករណ៍ត្រាំកក់/ក្រាំងតាចាន់ និងទំនប់១មករា) ដែលបង្កើតបានជាទីតាំងឧក្រិដ្ឋកម្ម "អប្បបរមា" ដែលត្រូវតែដាក់បញ្ចូលដើម្បីឆ្លើយតបទៅនឹងដីកាបង្គាប់របស់អង្គជំនុំជម្រះតុលាការកំពូល។ សហព្រះរាជអាជ្ញាក៏ស្នើផងដែរឲ្យដាក់បញ្ចូលនៅក្នុងវិសាលភាពនៃសំណុំរឿងលេខ០០២/០២ នូវទីតាំងឧក្រិដ្ឋកម្មចំនួនបីបន្ថែមទៀតអាចឲ្យធ្វើការជំនុំជម្រះក្ដីទៅបានដោយឆាប់រហ័ស និងអាចធ្វើឲ្យការជំនុំជម្រះក្ដីវគ្គទីពីរនេះ មានតំណាងកាន់តែខ្លាំងច្រើនថែមទៀតនៃដីកាបញ្ជូនរឿងទៅជំនុំជម្រះនៃសំណុំរឿងលេខ០០២។ ទីតាំងឧក្រិដ្ឋកម្មទាំងបីដែលបានស្នើសុំនោះ គឺមាន ***ការដ្ឋានសាងសង់ព្រលានយន្តហោះកំពង់ឆ្នាំង, មន្ទីរសន្តិសុខអូរកន្សែង,*** និង ***មន្ទីរសន្តិសុខភ្នំក្រោល។***

១៦- ការដាក់បញ្ចូលនូវទីតាំងឧក្រិដ្ឋកម្មទាំបីនេះ មុខជានឹងធ្វើឲ្យការជំនុំជម្រះលើសំណុំរឿងលេខ០០២/០២ កាន់តែមានលក្ខណៈតំណាងទាក់ទងនឹងភូមិសាស្ត្រកាន់តែខ្លាំងថែមទៀត ដោយការដាក់បន្ថែមនូវទីតាំងនានាពីភូមិភាគបស្ចឹម, ឥសាន និងពីតំបន់១០៥ (តំបន់មណ្ឌលគីរី) ចូលទៅក្នុងទីតាំងឧក្រិដ្ឋកម្មមួយដែលតំណាងឲ្យភូមិភាគនីរតី (ត្រាំកក់ ក្រាំងតាចាន់) ភូមិភាគបូព៌ា (ការធ្វើបាបជនជាតិចាម និងវៀតណាម), ភូមិភាគឧត្តរចាស់/កណ្ដាល (ការធ្វើបាបជនជាតិចាម , ទំនប់១មករា) និងភូមិភាគពាយ័ព្យ (ទួលពោធិ៍ជ្រៃ និងការជម្លៀសប្រជាជនចេញតំណាក់កាលទីពីរ)។ ការណ៍នេះមុខជានឹងធ្វើឲ្យប្រាកដថាទីតាំងឧក្រិដ្ឋកម្មមន្ទីរសន្តសុខ នៅក្នុងសំណុំរឿងលេខ០០២/០២ មានរួមបញ្ចូលនូវមន្ទីរសន្តិសុខថ្នាក់ស្រុក (ក្រាំងតាចាន់), ពន្ធនាគាររបស់ថ្នាក់កងពលធំនៃកងទ័ពបដិវត្តកម្ពុជា (អូរកន្សែង),មន្ទីរសន្តិសុខមួយរបស់តំបន់ស្វយត (ភ្នំក្រោល) និងមន្ទីរសន្តិសុខរបស់ថ្នាក់កំពូលដែលបានរាយការណ៍ដោយផ្ទាល់ជូនគណៈកម្មាធិការអចិន្ត្រៃយ៍(មន្ទីរស-២១)។

១៧- សហព្រះរាជអាជ្ញាកត់សម្គាល់ផងដែរថា អង្គជំនុំជម្រះសាលាដំបូងបានស្តាប់រួចមកហើយនូវភស្តុតាងនានាដែលពាក់ព័ន្ធនឹងទីតាំងឧក្រិដ្ឋកម្មដែលបានស្នើឡើងបន្ថែមចំនួនបី នៅក្នុងសំណុំរឿង ០០២/០១ ដែលភស្តុតាងទាំងនោះ រួមមាន សក្ខីកម្មសាក្សីជាអតីតលេខាស្រុក១០៥ (សៅ សារុន) កម្មាភិបាលម្នាក់ដែលធ្លាប់នបានធ្វើការងារនៅក្នុងតំបន់នោះ (ខាំ ផាន់ Kham Phan), ប្រធានមន្ទីរសន្តិសុខអូរកន្សែងនៃកងពលធំលេខ៨០១ (ឆោម សែ Chhaom Se), និងអតីតអនុលេខានៃកងពលធំនោះ (អ៊ុង រ៉េន Ung Ren)។ ផែនការធ្វើសវនាការលម្អិតដែលបានស្នើឡើងនឹងដាក់ជូននៅមុនពេលធ្វើកិច្ចប្រជុំរៀបចំសវនាការ ហើយសហព្រះរាជអាជ្ញារំពឹងទុកថា សាក្សីបន្ថែមដែលសហព្រះរាជអាជ្ញានឹងស្នើសុំដែលទាក់ទិននិងទីតាំងឧក្រិដ្ឋកម្មចំនួនបីនោះ នឹងត្រូវការពេលវេលាធ្វើសវនាការសរុបចំនួន១៤ថ្ងៃប៉ុណ្ណោះ។ លើសពីនេះ អង្គជំនុំជម្រះសាលាដំបូងអាចរក្សាទុកដដែលនូវសិទ្ធិអំណាចដើម្បីធ្វើការបំបែកកិច្ចដំណើរការនីតិវិធីលើទីតាំងឧក្រិដ្ឋកម្មណាមួយ ឬទាំងអស់បាននៅក្នុងអម្លុងពេលជំនុំជម្រះក្តី បើសិនជាមានលេចឡើងនូវកាលៈទេសៈផ្សេងៗ ដែលធ្វើឲ្យមានការចាំបាច់ត្រូវជំរុញឲ្យបំពេញសវនាការការជំនុំជម្រះក្តីលើសំណុំរឿងលេខ០០២/០១ ឲ្យបានចប់សព្វគ្រប់យ៉ាងឆាប់រហ័សនោះ[22]។

១៨- ជារួម ទីតាំងឧក្រិដ្ឋកម្ម ឬឧប្បត្តិហេតុនានាដែលត្រូវបានស្នើឡើងដោយសហព្រះរាជអាជ្ញា ដើម្បីដាក់បញ្ចូលនៅក្នុងសំណុំរឿងលេខ០០២/០២ ព្រមជាមួយនឹងកថាខណ្ឌនានានៃដីកាដំណោះស្រាយដែលពាក់ព័ន្ធរបស់វា គឺមានដូចខាងក្រោមនេះ៖

*(ក) មន្ទីរសន្តិសុខស-២១ (កថាខណ្ឌពីទី៤១៥-៤៧៥)។*

*(ខ) ការធ្វើបាបជនជាតិវៀតណាម (កថាខណ្ឌពីទី៧៩១-៨៣១)។*

*(គ) ការធ្វើបាបជនជាតិចាម (កថាខណ្ឌទី២៦៦, ២៦៨, ២៨១, ៧៤៥-៧៧០, និងទី៧៧៦-៧៩០)។*

[22] ឯកសារលេខ **E284/4/8** សេចក្តីសម្រេច លើបណ្តឹងសាទុក្ខភ្លាមៗ ប្រឆាំងនឹងសេចក្តីសម្រេចលើកទីពីររបស់អង្គជំនុំជម្រះសាលាដំបូងស្តីពីការបំបែកកិច្ចដំណើរការនីតិវិធី លើសំណុំរឿងលេខ០០២, ចុះថ្ងៃទី២៥ វិច្ឆិកា ២០១៣, កថាខណ្ឌទី៦៨ [" ទាក់ទងនឹងការគ្រប់គ្រងដ៏មានប្រសិទ្ធភាព ដែលត្រូវបានគេយល់ថាឧបធារណ៍ដែលថា អាចលប់លើវិសាលភាពនៃសំណុំរឿងលេខ០០២/០១ ត្រូវតែជាតំណាងឲ្យដីកាបញ្ជូនរឿងទៅជំនុំជម្រះ"]។

*(ឃ) សហករណ៍ត្រាំកក់/មន្ទីរសន្តិសុខក្រាំងតាចាន់ រួមបញ្ចូលទាំងការធ្វើបាបពុទ្ធសាសនិកជន និងអាពាហ៍ពិពាហ៍ដោយបង្ខំ (កថាខណ្ឌទី៣០-៣២២, ៤៨៩-៥១៥, ៧៤០-៧៤៣, និងទី៨៤២-៨៦០។*

*(ង) ការដ្ឋានទំនប់១មករា (កថាខណ្ឌទី ៣៥១-៣៦៨)។*

*(ច) ការដ្ឋានសាងសង់ព្រលានយន្តហោះកំពង់ឆ្នាំង (កថាខណ្ឌទី ៣៨៣-៣៩៩)។*

*(ឆ) មន្ទីរសន្តិសុខអូរកន្សែង (កថាខណ្ឌទី ៥៨៩-៦២៤)។ និង*

*(ជ) មន្ទីរសន្តិសុខភ្នំក្រោល (កថាខណ្ឌទី៦២៥-៦៤៣)។*

អង្គជំនុំជម្រះសាលាដំបូងចាំបាច់ក៏ត្រូវដាក់បញ្ចូលទៅក្នុងវិសាលភាពនៃសំណុំរឿង០០២/០២ ផងដែរ នូវកថាខណ្ឌនានានៅក្នុងដីកាដំណោះស្រាយ ចាប់តាំងពីផ្នែកសហឧក្រិដ្ឋកម្មរួម និងផ្នែកតួនាទីរបស់ជនជាប់ចោទទាក់ទងទៅនឹងសហករណ៍ និងការដ្ឋាននានា[23], មន្ទីរសន្តិសុខ និងទីកន្លែងសម្លាប់មនុស្ស[24], ការប្រព្រឹត្តិទៅលើជនជាតិចាម ការប្រព្រឹត្តលើជនជាតិវៀតណាម និងលើពុទ្ធសាសនិក[25], និងបទប្បញ្ញត្តិស្តីពីការរៀបអាពាហ៍ពិពាហ៍[26], ក៏ដូចជា ការចោទប្រកាន់នានាដែលទាក់ទងទៅនឹងជម្លោះប្រដាប់អាវុធផងដែរ[27]។

១៩- តាមសំណើរបស់សហព្រះរាជអាជ្ញា ការដាក់បញ្ចូលគ្នានូវសវនាការលើសំណុំរឿង០០២/០១ និងសំណុំរឿង០០២/០២ នឹងគ្របដណ្តប់លើគ្រប់បទចោទទាំងអស់ ដែលបានចោទប្រកាន់នៅក្នុងដីកាដំណោះស្រាយនៃសំណុំរឿង០០២ទាំងមូល។ ការចោទប្រកាន់លើបទឧក្រិដ្ឋទាំងនេះ នឹងត្រូវបានគ្របដណ្តប់ដោយសវនាការលើភស្តុតាងនានាពាក់ព័ន្ធនឹង៖ ការជម្លៀសដោយបង្ខំចំនួនពីរ ក្នុងចំណោមការជម្លៀសដោយបង្ខំចំនួនបី ដែលមាននៅក្នុងដីកាដំណោះស្រាយនៃសំណុំរឿង០០២, ការដ្ឋានពលកម្ម ឬសហករណ៍ ចំនួនបី ក្នុងចំណោមការដ្ឋានពលកម្ម ឬសហករណ៍ចំនួនប្រាំមួយ,

[23] **D427** ដីកាដំណោះស្រាយ, កថាខណ្ឌ ១៦៨-១៧៧ [JCE], កថាខណ្ឌ ៩០៣-៩១៥ [នួន ជា], កថាខណ្ឌ ១១៦៤-១១៧១ [ខៀវ សំផន]។

[24] *ដដែលដូចខាងលើ* ត្រង់កថាខណ្ឌ ១៧៨-២០៤ [JCE], កថាខណ្ឌ ៩១៦-៩៧៤ [នួន ជា], កថាខណ្ឌ ១១៧២-១១៩០ [ខៀវ សំផន]។

[25] *ដដែលដូចខាងលើ* ត្រង់កថាខណ្ឌ ២០៥-២១៥ [JCE], កថាខណ្ឌ ៩៧៥-៩៧៦, ៩៧៨-៩៩០ [នួន ជា], កថាខណ្ឌ ១១៩១-១១៩២, ១១៩៤-១១៩៨ [ខៀវ សំផន]។

[26] *ដដែលដូចខាងលើ* ត្រង់កថាខណ្ឌ ២១៦-២២០ [JCE], កថាខណ្ឌ ៩៩១-៩៩២ [នួន ជា], កថាខណ្ឌ ១១៩៩ [ខៀវ សំផន]។

[27] *ដដែលដូចខាងលើ* ត្រង់កថាខណ្ឌ ១៥០-១៥៥, ៩៩៣, ១២០០។

មន្ទីរសន្តិសុខ ឬទីកន្លែងសម្លាប់មនុស្សចំនួនប្រាំ ក្នុងចំណោមមន្ទីរសន្តិសុខ ឬទីកន្លែងសម្លាប់មនុស្សចំនួនដប់បួន, ក្រុមគោលដៅទាំងអស់ចំនួនបួន (ក្រុមអតីតមន្ត្រីរដ្ឋការសាធារណរដ្ឋខ្មែរ, ក្រុមព្រះពុទ្ធសាសនា, ក្រុមចាម និងក្រុមវៀតណាម) និងការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ។ **ឧបសម្ព័ន្ធ** ក ដែលមានភ្ជាប់មកនេះ គឺជាតារាងដែលមានចុះជាបញ្ជីនូវឧក្រិដ្ឋកម្មនានា ដែលបានចោទប្រកាន់នៅក្នុងសំណុំរឿង០០២ ដោយមានទីកន្លែង ឬឧប្បត្តិហេតុឧក្រិដ្ឋកម្មដែលបទឧក្រិដ្ឋនីមួយៗ ត្រូវបានចោទប្រកាន់ផងដែរ ដូចដែលបានបញ្ជាក់យ៉ាងច្បាស់ ចាប់ពីកថាខណ្ឌ១៣៣៥ រហូតដល់កថាខណ្ឌ១៥២០ នៅក្នុងដីកាដំណោះស្រាយ។

២០- ដូចដែលបានពិភាក្សាបន្ថែមទៀតនៅខាងក្រោម សហព្រះរាជអាជ្ញាសន្និដ្ឋានថា សវនាការដែលបានស្នើលើសំណុំរឿង០០២/០២ អាចនឹងត្រូវបានបញ្ចប់នៅក្នុងថិរវេលាមួយ ដ៏ឆាប់រហ័សយ៉ាងសមហេតុសមផល - គឺរយៈពេលសវនាការយ៉ាងខ្លីចំនួន១២ខែ និងមិនលើសពី១៨ខែនោះឡើយ។

## ***ផែនការសវនាការរបស់ការិយាល័យសហព្រះរាជអាជ្ញា និងការប៉ាន់ស្មានពីថិរវេលា***

២១- សហព្រះរាជអាជ្ញានឹងដាក់ជូននៅមុនសម្រាប់កិច្ចប្រជុំរៀបចំសវនាការ នូវផែនការធ្វើសវនាការលើទីតាំងឧក្រិដ្ឋកម្មនានា ដែលត្រូវស្នើដាក់បញ្ចូលទៅក្នុងសំណុំរឿង០០២/០២ ដែលមានបញ្ចូលនូវបញ្ជីបឋម បញ្ជីបណ្តោះអាសន្ន នូវឈ្មោះទាំងឡាយរបស់សាក្សី ដើមបណ្តឹងរដ្ឋប្បវេណី និងអ្នកជំនាញនានា ដែលសហព្រះរាជអាជ្ញាមានបំណងស្នើសុំសម្រាប់ទីតាំងឧក្រិដ្ឋកម្មនីមួយៗ និងមានការបែងចែកពេលវេលាដែលបានស្នើសុំសម្រាប់បុគ្គលនីមួយៗទាំងនោះផង។ ផែនការរបស់ការិយាល័យសហព្រះរាជអាជ្ញា អំពីការធ្វើសវនាការក៏នឹងមានការកំណត់អត្តសញ្ញាណលើសាក្សីនានាដែលបានលើកស្នើឡើងផងដែរទាក់ទងទៅនឹងតួនាទីរបស់ជនជាប់ចោទ និងអត្ថិភាពនៃសហឧក្រិដ្ឋកម្មរួម ក៏ដូចជា អ្នកជំនាញនានាផងដែរ ទាក់ទងទៅនឹងបញ្ហាផ្សេងៗដែលនឹងមានការលើកឡើងនៅក្នុងសំណុំរឿង០០២/០២។ សហព្រះរាជអាជ្ញាធ្វើការកត់សម្គាល់ថា ការពិនិត្យឡើងវិញ និងការវាយតម្លៃរបស់ខ្លួនលើសក្ខីកម្មរបស់សាក្សីចាំបាច់ គឺមានលក្ខណៈជាបន្តបន្ទាប់ ហើយថាបញ្ជីឈ្មោះសាក្សីជាស្ថាពរ នឹងដាក់ជូននៅក្រោយពេលដែលវិសាលភាពនៃសំណុំរឿង០០២/០២ ត្រូវបានកំណត់ និងដោយគោរពតាមកាលបរិច្ឆេទដែលអង្គជំនុំជម្រះបានកំណត់ សម្រាប់ការដាក់ជូននូវបញ្ជីឈ្មោះសាក្សី និងបញ្ជីឯកសាររបស់ភាគីនានា។

២២- ដូចដែលបានបញ្ជាក់នៅក្នុងឯកសារដែលបានដាក់កាលពីថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០១៣[28] សហព្រះរាជអាជ្ញាសន្និដ្ឋានថា ភស្តុតាងដែលបានទទួលយកនៅក្នុងសំណុំរឿង០០២/០១ រួមមាន សក្ខីកម្មរបស់សាក្សី ដើមបណ្តឹងរដ្ឋប្បវេណី និងអ្នកជំនាញនានាដែលបានបង្ហាញខ្លួននៅក្នុងសវនាការ គួរត្រូវពិចារណាថាជាផ្នែកមួយនៃកំណត់ហេតុក្នុងសំណុំរឿង០០២/០២ ដោយពុំចាំបាច់មានការដាក់សំណើណាមួយពីសំណាក់ភាគីនានាឡើយ។ អង្គជំនុំជម្រះសាលាដំបូងត្រូវផ្តល់ជូនភាគីនានា នូវសិទ្ធិក្នុងការស្នើសុំឲ្យកោះហៅសាជាថ្មីនូវសាក្សីនានានៃសំណុំរឿង០០២/០១ បើមានការបង្ហាញថា សក្ខីកម្មបន្ថែមពីបុគ្គលរូបនោះ ពិតជាមានលក្ខណៈចាំបាច់ ហើយថា កាលពីអំឡុងពេលសវនាការលើកទីមួយ ពួកគេមិនមានឱកាសសួរសាក្សីនូវសំណួរពាក់ព័ន្ធនានាទាំងនោះឡើយ។

២៣- សាក្សី ដើមបណ្តឹងរដ្ឋប្បវេណី និងអ្នកជំនាញនានាដែលបានស្នើសុំនៅក្នុងផែនការរបស់សហព្រះរាជអាជ្ញា អំពីការធ្វើសវនាការលើសំណុំរឿង០០២/០២ នឹងតម្រូវឲ្យមានការប្រើប្រាស់ពេលវេលាសវនាការ សរុប ចំនួនតិចជាង ១០០ថ្ងៃ។ ដោយមានការពិចារណាអំពី សាក្សី ដើមបណ្តឹងរដ្ឋប្បវេណី និងអ្នកជំនាញបន្ថែម ដែលអាចស្នើឡើងដោយជនជាប់ចោទ និងសហមេធាវីនាំមុខដើមបណ្តឹងរដ្ឋប្បវេណី ដូច្នេះសវនាការលើទីតាំងឧក្រិដ្ឋកម្មដែលបានស្នើឡើងដោយសហព្រះរាជអាជ្ញា អាចនឹងត្រូវបានបញ្ចប់នៅពាក់កណ្តាលឆ្នាំ២០១៥។

២៤- ឯកសារទាំងឡាយដែលបានទទួលយកនៅក្នុងសំណុំរឿង០០២/០១ គួរត្រូវបានពិចារណាថាត្រូវទទួលយកធ្វើជាភស្តុតាងនៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង សម្រាប់ជាគោលបំណងនៃសវនាការលើសំណុំរឿង០០២/០២ អាស្រ័យលើសិទ្ធិរបស់ភាគីទាំងអស់ ក្នុងការដាក់នូវតម្លៃជាភវនីយភាពនៃភស្តុតាងទាក់ទងនឹងបទចោទនានានៅក្នុងសវនាការលើកទីពីរ។ វិធីសាស្ត្រនេះសមស្របទៅនឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង ក្នុងការធ្វើឲ្យសំណុំរឿង០០២/០១ ក្លាយទៅជាមូលដ្ឋានមួយសម្រាប់សវនាការជាបន្តបន្ទាប់ទៀត។ វាក៏នឹងមានន័យថា គេត្រូវការពេលវេលាត្រឹមកម្រិតអប្បបរមាសម្រាប់ធ្វើសវនាការលើកទីពីរនេះ ទៅលើការទទួលយកភស្តុតាងជាឯកសារបន្ថែម។ ភាគច្រើននៃឯកសារសហកាលដែលបានមកពីមន្ទីរស-២១ និងស្រុកត្រាំកក់

[28] **E301/1** មតិរបស់សហព្រះរាជអាជ្ញា លើរបៀបវារៈនៃកិច្ចប្រជុំរៀបចំសវនាការ សម្រាប់សំណុំរឿង ០០២/០២, ២០ វិច្ឆិកា ២០១៣, កថាខណ្ឌ ២។

ត្រូវបានអង្គជំនុំជម្រះទទួលយករួចជាស្រេចហើយ នៅក្នុងសំណុំរឿង០០២/០១ ហើយឯកសារដែលនៅសេសសល់ពីទីតាំងទាំងនោះ គឺជាប្រភេទឯកសារដូចគ្នាទៅនឹងឯកសារនានាដែលត្រូវបានកំណត់រួចហើយថាអាចទទួលយកបាន។ ឯកសារថ្មីៗ ទាក់ទងទៅនឹងទីតាំងឧក្រិដ្ឋកម្មផ្សេងទៀតដែលបានស្នើនៅក្នុងសំណុំរឿង០០២/០២ គឺភាគច្រើនកម្រិតចំពោះកំណត់ហេតុស្តាប់ចម្លើយសាក្សី ដែលពាក់ព័ន្ធនឹងទីតាំងឧក្រិដ្ឋកម្មទាំងនោះ។

## *បញ្ញត្តិនៃការដកចេញទីតាំងឧក្រិដ្ឋកម្ម និងឧប្បត្តិហេតុ*

២៥- សេចក្ដីសម្រេចថ្មីៗរបស់អង្គជំនុំជម្រះតុលាការកំពូលបានបញ្ជាក់យ៉ាងច្បាស់ថា អង្គជំនុំជម្រះសាលាដំបូងមិនមានកាតព្វកិច្ចធ្វើសវនាការលើគ្រប់ទីតាំងឧក្រិដ្ឋកម្ម គ្រប់ព្រឹត្តិការណ៍ ឬគ្រប់ឧប្បត្តិហេតុទាំងអស់ដែលមាននៅក្នុងដីកាដំណោះស្រាយលើសំណុំរឿង០០២នោះទេ ដោយហេតុថា "ការបញ្ចូលគ្នានៃសំណុំរឿង០០២/០១ និង០០២/០២" គឺ "ក្លាយជាតំណាងសមហេតុផលនៃដីកាបញ្ជូនរឿងទៅជំនុំជម្រះ"[29]។ អង្គជំនុំជម្រះតុលាការកំពូលបានកំណត់បន្ថែមទៀតថា ការអនុវត្តដ៏តឹងរឹងនូវគោលការណ៍នៃការចោទប្រកាន់ដែលជាលក្ខខណ្ឌចាំបាច់ គឺមិនបានធានាទេក្នុងក្របខណ្ឌផ្លូវច្បាប់នៅអវតក[30]។

២៦- ដូច្នេះ ដោយអនុលោមតាមបទដ្ឋានអន្តរជាតិ អង្គជំនុំជម្រះសាលាដំបូងមានជម្រើសក្នុងការអនុវត្តសិទ្ធិដកចេញនូវបទចោទនានា ដោយមាន "ការព្រមព្រៀង" ពីសហព្រះរាជអាជ្ញា នៅពេលដែល "ផលប្រយោជន៍នៃយុត្តិធម៌តម្រូវ"[31]។ អង្គជំនុំជម្រះតុលាការកំពូលក៏បានកំណត់ផងដែរថា នីតិវិធីរបស់តុលាការ ICTY ក្នុងការ "កាត់បន្ថយបទចោទ" គឺអាចអនុញ្ញាតអង្គជំនុំជម្រះនេះ ធ្វើជា "លិខិតុបករណ៍សម្រាប់រៀបចំសវនាការ"[32]។ សហព្រះរាជអាជ្ញាមិនស្នើឲ្យទម្លាក់ "បទចោទ" ណាមួយចេញពីដីកាដំណោះស្រាយឡើយ ផ្ទុយទៅវិញ ដើម្បីជាផលប្រយោជន៍នៃការជំនុំជម្រះក្តី

---

[29] **E284/4/8** សេចក្តីសម្រេចលើបណ្តឹងសាទុក្ខភ្លាមៗប្រឆាំងនឹងសេចក្តីសម្រេចលើកទីពីរ របស់អង្គជំនុំជម្រះសាលាដំបូង ស្តីពីការបំបែកកិច្ចដំណើរការនីតិវិធីនៃសំណុំរឿង ០០២, ២៥ វិច្ឆិកា ២០១៣, កថាខណ្ឌ ៧០។

[30] *ដដែលដូចខាងលើ* ត្រង់កថាខណ្ឌ ៦១-៦២។

[31] *ដដែលដូចខាងលើ* ត្រង់កថាខណ្ឌ ៦២។

[32] *ដដែលដូចខាងលើ* ត្រង់កថាខណ្ឌ ៦៣។

ឆាប់របហ័ស និងមានតំណាងនោះ សហព្រះរាជអាជ្ញាកម្រិតនៅលើភស្តុតាង សម្រាប់បង្ហាញបទចោទនីមួយៗ ដោយដកចេញនូវឧប្បត្តិហេតុ និងទីកន្លែងឧក្រិដ្ឋកម្មជាក់លាក់មួយចំនួន ពីសវនាការ។

២៧- តាមផែនការធ្វើសវនាការដែលការិយាល័យសហព្រះរាជអាជ្ញាបានស្នើឡើង ទីតាំងឧក្រិដ្ឋកម្ម ឬឧប្បត្តិហេតុនានា ដែលអាចដកចេញពីសវនាការលើសំណុំរឿង០០២/០២ គឺមាន៖ ដំណាក់កាលទីបីនៃការជម្លៀសដោយបង្ខំ, ទំនប់ត្រពាំងថ្ម, ការដ្ឋានពលកម្មស្រែអំបិល និងព្រៃស, មន្ទីរសន្តិសុខ សង់កោះខ្យង ព្រៃដំរីស្រុត វត្តគីរីរម្យ ភូមិភាគឧត្តរ វត្តផ្លុក គោកក្ដួច និងមន្ទីរសន្តិសុខក្រូចឆ្មារ, ទីកន្លែងសម្លាប់មនុស្ស ស្រុក១២ និងស្ទឹងតូច, និងការលុកលុយរបស់កងទ័ពបដិវត្តកម្ពុជាចូលទៅក្នុងប្រទេសវៀតណាម។

២៨- ដោយមិនគិតពីដំណើរការនីតិវិធីតាមផ្លូវច្បាប់ជាក់លាក់ដែលយកមកអនុវត្តជាចុងក្រោយ ទាក់ទងនឹងទីកន្លែងឧក្រិដ្ឋកម្ម និងឧប្បត្តិហេតុដែលមិនបានដាក់បញ្ចូលនោះទេ សហព្រះរាជអាជ្ញាមិនសង្ឃឹមថានឹងមានសវនាការលើកទីបីពាក់ព័ន្ធទៅនឹងបញ្ហាទាំងនេះ លើជនជាប់ចោទនោះទេ។ សំណុំរឿង ០០២/០២ ដោះស្រាយលើគ្រប់ការចោទប្រកាន់នៃឧក្រិដ្ឋកម្មទាំងអស់ ដែលនៅសេសសល់ ដែលមាននៅក្នុងដីកាដំណោះស្រាយដែលមិនត្រូវបានគ្របដណ្តប់នៅក្នុងសំណុំរឿង០០២/០១ ដោយជ្រើសរើសយកទីកន្លែងឧក្រិដ្ឋកម្មជាតំណាងសម្រាប់បទចោទនីមួយៗ។ ដូច្នេះ ដើម្បីផ្តល់នូវភាពច្បាស់លាស់មួយជូនដល់ជនរងគ្រោះ ជនជាប់ចោទ និងម្ចាស់អំណោយ សហព្រះរាជអាជ្ញាសន្និដ្ឋានថា សំណុំរឿង០០២/០២ ត្រូវតែជាសវនាការបញ្ចប់លើរឿងក្ដីរបស់ នួន ជា និង ខៀវ សំផន នៅ អវតក លើដីកាដំណោះស្រាយនៃសំណុំរឿង០០២។

| កាលបរិច្ឆេទ | ឈ្មោះ | ទីកន្លែង | ហត្ថលេខា |
|---|---|---|---|
| ថ្ងៃទី៥ ខែធ្នូ ឆ្នាំ២០១៣ | **លោកស្រី ជា លាង**<br>សហព្រះរាជអាជ្ញាជាតិ | ភ្នំពេញ | [signature] |
| | **លោក** Nicholas KOUMJIAN<br>សហព្រះរាជអាជ្ញាអន្តរជាតិ | | [signature] |